

*កសិករម្នាក់នៅក្នុងខេត្តស្វាយរៀង បានធ្វើការតស៊ូពុះពារដើម្បីបំពេញនូវតំរូវការគ្រួសាររបស់គាត់។ គាត់ជួបបញ្ហាជាច្រើនក្នុងការដាំបន្លែ ធ្វើស្រែ និងចញ្ចឹមមាន់ ដោយសារជំងឺដែលកើតមានលើសត្វ ក៏ដូចជាសត្វល្អិតស៊ីដំណាំផងដែរ។ លើសពីនេះទៅទៀត ប្រាក់ចំណូលដែលបានមកសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់គាត់ គឺបានមកពីស្វាមីរបស់គាត់តែប៉ុណ្ណោះ ដោយសារតែស្វាមីរបស់គាត់បានធ្វើការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ខណៈពេលដែលខ្លួនគាត់ផ្ទាល់មិនអាចរកប្រាក់ចំណូល ដើម្បីទ្រទ្រង់គ្រួសាររបស់គាត់បានឡើយ ហើយវាជាអ្វីដែលគាត់គិតថាគួរឲ្យអាម៉ាស់។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីឆ្នាំ២០១៥មក ជីវភាពគ្រួសាររបស់គាត់បានប្រសើរគួរឲ្យកត់សម្គាល់ បន្ទាប់ពីគាត់បានចុះឈ្មោះជាសមាជិកនៃក្រុមជួយខ្លួនឯង (ក.ជ.ខ) ជាមួយនឹងគម្រោងអភិវឌ្ឍន៍គ្រួសារ និងសាលារៀន (ហ្វាស) របស់អង្គការអោយស៊ីស៊ី។*

ដោយសារតែបានឮព័ត៌មានតាមរយៈអ្នកធ្វើការងារស្ម័គ្រចិត្តក្នុងកិច្ចការអភិវឌ្ឍន៍សហគមន៍ និងពីអ្នកជិតខាង អំពីអត្ថប្រយោជន៍ជាសមាជិករបស់ ក.ជ.ខ គាត់បានសម្រេចចិត្តចុះឈ្មោះចូលរួមជាមួយ ក.ជ.ខ នៅឆ្នាំ២០១៥។ ចាប់តាំងពីពេលនោះមក គាត់និងក្រុមគ្រួសាររបស់គាត់បានទទួលនូវការគាំទ្រខាងផ្នែកហិរញ្ញវត្ថុ តាមរយៈការសន្សំប្រាក់ និងប្រាក់កម្ចី។ ក.ជ.ខ ក៏បានផ្តល់នូវជំនាញ និងវគ្គបណ្តុះបណ្តាលខាងផ្នែកបច្ចេកទេសទៅដល់គ្រួសាររបស់គាត់ដូចជា ការចិញ្ចឹមសត្វ (ដូចជាសត្វមាន់ និងត្រី) និង ការបណ្តុះបណ្តាលផ្សេងៗទៀតទាក់ទងនឹងកសិកម្ម ការថែទាំសុខភាព អនាម័យ យ៉េនឌ័រ ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ សិទ្ធិកុមារ និងការការពារកុមារ។ មុនពេលក្លាយជាសមាជិកនៃ ក.ជ.ខ គាត់មិនដែលទទួលបានឱកាសក្នុងការចូលរួមវគ្គបណ្តុះបណ្តាលបែបនេះទេ ដោយសារតែគាត់ផ្តោតទៅលើតែការដាំបន្លែ និងចិញ្ចឹមមាន់តាមបែបប្រពៃណីតែប៉ុណ្ណោះ។ ការធ្វើបែបនេះហើយ ទើបគាត់ប្រឈមមុខនឹងបញ្ហាជាច្រើនដូចជា ជំងឺដែលកើតមានលើសត្វ សត្វល្អិត និងកង្វះបច្ចេកទេសកសិកម្មសម័យទំនើប។ លើសពីនេះទៀត ប្រភពចំណូលគ្រួសាររបស់គាត់គឺមានតែមួយគត់ គឺបានមកពីស្វាមីរបស់គាត់ដែលចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ នេះហើយ ជាអ្វីដែលធ្វើឲ្យគាត់ពិបាកចិត្ត ហើយនេះក៏ជាអ្វីដែលជំរុញឲ្យគាត់ចូលរួមជាសមាជិករបស់ ក.ជ.ខ។

ចាប់តាំងពីពេលដែលគាត់ និងស្វាមីរបស់គាត់បានធ្វើការប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីៗដែលបានមកពី គម្រោង ហ្វាស របស់អាយស៊ីស៊ី ប្តីរបស់គាត់មិនចាំបាច់ធ្វើការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសទៀតទេ។ ជាលទ្ធផល គ្រួសាររបស់គាត់ អាចបង្កើនទិន្នផលមាន់របស់ពួកគាត់បាន ដោយសារតែពួកគាត់ដឹងពីរបៀបថែទាំមាន់ ដោយផ្តល់វ៉ាក់សាំងបានត្រឹមត្រូវ ចេះឲ្យអាហារដែលមានគុណភាព រក្សាវដ្តចំណីអាហារបានល្អ ហើយនិងសំអាតទ្រុងបានទៀងទាត់ថែមទៀត។ ទាំងអស់នេះហើយ គឺបានធ្វើឲ្យគ្រួសាររបស់គាត់អាចរកប្រាក់បានប្រហែលជា ៣៥៥ដុល្លារ ក្នុងរយៈពេលត្រឹមតែប្រាំមួយខែពីការលក់មាន់។

ឥឡូវនេះ ពួកគាត់មានលទ្ធភាពក្នុងការកែលម្អរបបអាហារប្រចាំថ្ងៃ មានលទ្ធភាពក្នុងការផ្គត់ផ្គង់ការអប់រំទៅដល់កូន និងរក្សាប្រាក់ចំណូលតិចតួចសម្រាប់ការសន្សំទៅក្នុង ក.ជ.ខ។ ដើម្បីបង្កើនប្រាក់ចំណូល និងផ្គត់ផ្គង់ម្ហូបអាហារដល់គ្រួសាររបស់គាត់បន្ថែមទៀតនោះ គាត់និងគ្រួសាររបស់គាត់ បាននឹងកំពុងតែធ្វើការចិញ្ចឹមត្រី និងដាំបន្លែថែមទៀត។ ចំពោះផែនការនាពេលអនាគត់ គាត់មានគម្រោងចង់ពង្រីកកសិដ្ឋានរបស់គាត់បន្ថែមទៀត ដើម្បីបង្កើនទិន្នផលកសិកម្ម និងដើម្បីបង្កើនជីវភាពគ្រួសាររបស់គាត់។ គ្រួសាររបស់គាត់ ក៏កំពុងជួយទៅដល់សមាជិក ក.ជ.ខ ដ៏ទៃផ្សេងទៀត ក្នុងការបង្កើតប្រាក់ចំណូលតាមរយៈការចែករំលែកចំណេះដឹង និងជំនាញលើវិស័យកសិកម្ម ហើយក៏លើកទឹកចិត្តដល់សមាជិកផ្សេងៗទៀតឲ្យធ្វើការប្រើប្រាស់ធនធានដែលមានស្រាប់នៅក្នុងសហគមន៍ ដើម្បីកាត់បន្ថយការចំណាយដែលមិនចាំបាច់។

វាពិតជាមានផលប៉ះពាល់យ៉ាងខ្លាំង នៅពេលដែលមើលឃើញថាប្រជាជននៅក្នុងសហគមន៍ ជាពិសេសសមាជិក ក.ជ.ខ អាចកែលម្អជីវភាពរបស់ខ្លួនផ្ទាល់បាន តាមរយៈការចូលរួមនៅក្នុងសកម្មភាពផ្សេងៗរបស់ ក.ជ.ខ ដែលសមាជិកនីមួយៗទទួលបាននូវចំណេះដឹង និងជំនាញបច្ចេកទេសដែលចាំបាច់ ក៏ដូចជាទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ។ វាពិតជាមានការលើកទឹកចិត្ត នៅពេលដែលឃើញថាសហគមន៍បានធ្វើការរួមគ្នា ដើម្បីទទួលបាននូវអត្ថប្រយោជន៍រួម និងជីវភាពរស់នៅប្រកបដោយចីរភាព។

កាលបរិច្ឆេទ៖ ធ្នូ ២០១៨